# អង្គការសហប្រជាជាតិដោះស្រាយការរំលោភសិទ្ធិមនុស្សដោយរបបខ្មែរក្រហម
# មុនកងទ័ពវៀតណាមចូលមកកម្ពុជា

គេតែងតែឮជារឿយៗនូវការចោទប្រកាន់ពីថ្នាក់ដឹកនាំក៏ដូចប្រជារាស្ត្រខ្មែរខ្លះ ថាអង្គការសហប្រជាជាតិមិនបានខ្វល់ខ្វាលទេអំពីការរំលោភសិទ្ធិមនុស្ស និងការសម្លាប់រង្គាលប្រជាពលរដ្ឋខ្មែរដោយរបបខ្មែរក្រហមមុនកងទ័ពវៀរណាមចូលមករំលំរបបនេះ។ ការចោទប្រកាន់ ខ្លះបន្តថា ដល់ក្រោយគេវាយកំទេចខ្មែរក្រហមឲ្យអស់ហើយ ទើបអង្គការសហប្រជាជាតិមកខ្វល់ខ្វាយខ្លាំងអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងអំពីការកាត់ទោសខ្មែរក្រហម។

**តើអង្គការសហប្រជាជាតិពិតជាមិនបានខ្វល់ខ្វាយដូចគេចោទឬ ?**

តុលាការកាត់ទោសខ្មែរក្រហមបានបង្ហាញនូវការពិតហើយក្នុងរឿងនេះ ដែលបានធ្វើការចោទប្រកាន់ទាំងឡាយខាងលើឱ្យទៅជាការបំភ្លៃនៃការពិតនេះទាំងស្រុង ។ នាពេលព្រឹកនៃថ្ងៃទី២២ ខែវិច្ឆិកាឆ្នាំ២០១១នេះ សហមេធាវីអន្តរជាតិអមតុលាការនេះ គឺលោក អង់ទ្រូ កេលឡេ (Andrew Cailley) បានធ្វើសេចក្តីថ្លែងការណ៍បើកការចោទប្រកាន់របស់លោកទៅលើជនជាប់ចោទឈ្មោះ នួន ជា អៀង សារី និងខៀវ សំផន ។ នៅក្នុងសេចក្តីថ្លែងការណ៍នោះ លោក អង់ទ្រូ កេលឡេ បានលើកឡើងនូវចំណុចមួយក្នុងចំណុចដ៏ច្រើន ថា នៅខែមិនា និងកញ្ញា ឆ្នាំ១៩៧៨ ប្រទេសមួយចំនួនបានលើកយកការរំលោភសិទ្ធិមនុស្សដោយរបបខ្មែរក្រហមទៅពិនិត្យពិភាក្សាដើម្បីរិះរកវិធានការបញ្ចប់ការរំលោភនេះ ។ តាមសហមេធាវីអន្តរជាតិដដែលនេះ អៀង សារី ដែលជារដ្ឋមន្ត្រីក្រសួងការបរទេសខ្មែរក្រហម បានជំទាស់យ៉ាងខ្លាំង និងដោយប្រើភាសាយ៉ាងត្រគោះបោះបោកទៅនឹងអន្តរាគមនោះ ដោយចោទប្រកាន់ថាប្រទេសទាំងឡាយនោះលូកដៃចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសកម្ពុជា និងថែមទាំងប្រកាសថាប្រជាជនកម្ពុជានឹងកាប់ឱ្យម៉ត់ដូច"សាច់ចញ្ច្រាំ" នូវកលល្បិចទាំងអស់នោះ ។

តាមពិត របាយការណ៍ និងកំណត់ហេតុស្តីពីការលើកឡើងរបស់ប្រទេស និងអង្គការមិនមែនរដ្ឋាភិបាលសិទ្ធិមនុស្សអន្តរជាតិនានា និងកិច្ចប្រជុំពិភាក្សាពិនិត្យមើលអំពីការរំលោភសិទ្ធិមនុស្សនៅកម្ពុជាត្រូវបានចងក្រងនិងរក្សាទុកនៅក្នុងបណ្ណាល័យរបស់ គណៈកម្មការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ( United Nations Commission on Human Rights ) ដែលឥឡូវនេះមានឈ្មោះ ថាក្រុម

ប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ( United Nations Human Rights Council ) ។ ទាំងក្រុមប្រឹក្សានេះ ទាំងបណ្ណាល័យរបស់ខ្លួនមានទីស្នាក់ការនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ហើយស្ថិតនៅក្រោមចំណុះក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចរបស់អង្គការសហប្រជាជាតិ ។

ឯកសារទាំងឡាយនោះ បានបញ្ជាក់យ៉ាងច្បាស់ថា ប្រទេសនានាមួយចំនួន អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយចំនួន និងអង្គការសហប្រជាជាតិផ្ទាល់ មិនបាននៅប្រងើយ កន្តើយ និងមិនខ្វល់ខ្វាយអំពីការរំលោភសិទ្ធីមនុស្ស និងការសម្លាប់រង្គាលរបស់របបខ្មែរក្រហម ដូចដែលអ្នកមិនដឹងការពិត ឬដឹងការពិតហើយតែមិនទទួលយក ចេះតែចោទប្រកាន់ដាក់កំហុសទៅលើអង្គការសហប្រជាជាតិដោយបំពាននោះទេ ។

តាមរយៈឯកសារទាំងនោះ គេបានដឹងថា អន្តរាគមន៍ទាំងឡាយ ជាអាទ៍តាមរយៈគណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានចាប់ផ្តើមពីខែមីនា ឆ្នាំ១៩៧៨ គឺ១០ខែមុនកងទ័ពវៀតណាមចូលមករំលំរបបខ្មែរក្រហម និងបង្កើតរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ រដ្ឋាភិបាលខ្មែរក្រហមបានឆ្លើយតប និងតតាំង ដោយប្រមាថទៅនិងអន្តរាគមន៍ទាំងឡាយនោះ ។ សូមបញ្ជាក់ថានៅពេលនេះ អៀង សារី ដែលនៅពេលនោះជារដ្ឋមន្ត្រីការបរទេសខ្មែរក្រហម បានផ្ញើលិខិតឆ្លើយតបវែបកទៅវិញ ហើយបានជេរប្រមាថធ្ងន់ៗអសុរសជាងគេ ទៅលើប្រទេសអង់គ្លេស ដែលបានផ្តួចផ្តើមធ្វើអន្តរាគមន៍នោះមុន ហើយបានស្នើឱ្យមានយន្តការពិនិត្យការលំលោភសិទ្ធិមនុស្សនៅក្នុងរបបខ្មែរក្រហមទៀតផង ។ ការជេរប្រមាថនេះបានធ្វើអោយប្រទេសអង់គ្លេសនេះឈប់ទទួលស្គាល់ (derecognise ) រដ្ឋាភិបាលខ្មែរក្រហម បន្ទាប់ពីវៀតណាមចូលកាន់កាប់កម្ពុជា (តែក៏មិនទទួលស្គាល់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាដែរទេ)។

អន្តរាគមន៍របស់ប្រទេសនានា របស់អង្គការសិទ្ធមនុស្សអន្តរជាតិនានា និង របស់អង្គការសហប្រជាជាតិ មានសង្ខេបនៅក្នុងឯកសារមួយដែលកត់ត្រាទុកនូវព្រឹត្តិការណ៍ បច្ចុប្បន្ននានានៅក្នុងពិភពលោកនៅពេលនោះ ហើយដែលមានឈ្មោះថា *ឃីស៊ីង ខុនថិមផូរ៉ារី អាខាយវីស៍* (*Keesing's Contemporary Archives*) ចុះនៅថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៩ នៅទំព័រទី២៩៥៨៣ និងមានចំណងជើងថា "ការស៊ើបអង្កេតរបស់អង្គការសហប្រជាជាតិទៅលើការរំលោភសិទ្ធិមនុស្សនៅកម្ពុជា "។

ឯកសារនេះត្រូវបានបកប្រែសម្រួល និងមានភ្ជាប់អត្ថបទដើមជាភាសាអង់គ្លេសនៅខាងចុង ដូចខាងក្រោមនេះ៖

"ការស៊ើបអង្កេតអង្គការសហប្រជាជាតិទៅលើការរំលោភសិទ្ធិមនុស្សនៅកម្ពុជា

នៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៨ លោក អេវាន់ លាត់ ( Evan Luard ) ដែលជាអនុរដ្ឋលេខាធិការ ក្រសួងកិច្ចការបរទេស និង ខុមម៉ិនវែល(Commonwealth) នៃប្រទេសអង់គ្លេសបានស្នើទៅ គណៈកម្មការសិទ្ធិមនុស្ស (Human Rights Commission) របស់អង្គការសហប្រជាជាតិ សុំ ឲ្យមានការបង្កើតអង្គពិសេសមួយ ដើម្បីធ្វើការស៊ើបអង្កេតទៅលើការចោទប្រកាន់ថា មានការរំលោភសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។ ក្រោយពីប្រតិភូរបស់សហភាពសូវៀតបាន ប្រឆាំងនឹងសំណើនេះ ដោយប្រតិភូនេះចោទប្រកាន់ថា ការចោទប្រកាន់ដែលថា មានការរំលោភសិទ្ធិមនុស្សនៅកម្ពុជាទាំងនោះពុំមានមូលដ្ឋាន និងធ្វើឡើងដោយមានគោលបំណងនយោបាយ នោះមក គណៈកម្មការក៏សម្រេចនៅថ្ងៃទី៨ ខែមីនា សូមឲ្យរដ្ឋាភិបាលប្រទេសកម្ពុជាផ្តល់ ពត៌មានអំពីរបាយការណ៍ទាំងឡាយដែលមានការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ។

នៅថ្ងៃទី២២ ខែមេសា ក្រសួងការបរទេសប្រទេសកម្ពុជាបានចេញសេក្តីថ្លែងការមួយថ្កោលទោសគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលអង់គ្លេស ថាជា " ការលូកដៃចូលដ៏ស្អប់ខ្ពើម " និងចោទប្រកាន់ថា ជនជាតិអង់គ្លេសជាជនជាតិ " សាហាវ និងព្រៃផ្សៃបំផុត " ។

នៅថ្ងៃទី១៥ ខែកញ្ញា អនុគណៈកម្មការទប់ស្កាត់ការរើសអើង និងការពារជនជាតិភាគតិច (Subcommission on Prevention of Discrimination and Protection of Minorities) របស់ អង្គការសហប្រជាជាតិ បានអនុម័តសេចក្តីសម្រេចចិត្តមួយឲ្យមានការវិភាគមួយទៅលើឯកសារនានា សរុបចំនួន ១០០០ទំព័រ ស្តីអំពីការរំលោភសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ដែលរដ្ឋាភិបាលប្រទេសអង់គ្លេស អាមេរិច កាណាដា និងន័រវេស អង្គការលើកលែងទោសអន្តរជាតិ និងគណៈកម្មការអ្នកច្បាប់អន្តរជាតិ បានដាក់ជូនអនុគណៈកម្មការពិនិត្យ ។ សេចក្តីសម្រេចចិត្ត មួយនេះត្រូវបានអនុម័តដោយមានសម្លេង ១៥គាំទ្រ និង៣សម្លេងប្រឆាំង។ ប្រទេសប៊ុលហ្គារី ប្រទេសរូម៉ានី និងសហភាពសូវៀតបោះឆ្នោតប្រឆាំង ហើយប្រទេសស៊ៀរី និងប្រទេសទួគី បោះឆ្នោតអនុបវាទ។

នៅក្នុងទូរសារមួយច្បាប់ផ្ញើរទៅអង្គការសហប្រជាជាតិ លោក អៀង សារី បានបរិហារ សេចក្តីសម្រេចនេះថាជា "ការលូកដៃចូលដ៏អៀនខ្មាស" ទៅក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេស កម្ពុជា ហើយប្រកាសថា ប្រជាជន និងរដ្ឋាភិបាលប្រទេសកម្ពុជានឹង "កាប់ឲ្យហ្មត់ដូចសាច់ចិញ្ច្រាំនូវរាល់កលល្បិចឧក្រិដ្ឋរបស់ពពួកចក្រពត្តិ និងអ្នកកាន់ជើងវា" ។

ការវិភាគភស្តុតាងដែលបានដាក់ជូនគណៈកម្មការសិទ្ធិមនុស្សនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៧៩ បានស្រង់ការប៉ាន់ស្មាននានាថា យ៉ាងហោចណាស់មានមនុស្ស មួយលាននាក់បានស្លាប់ដោយមូលហេតុនានានៅក្នុងប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៧៥មក ។

នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៧៨ លោក អៀង សារី បានអញ្ជើញបណ្ឌិត គើត វ៉ាល់ហែម (Kurt Walheim) ដែលជាអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ឲ្យអញ្ជើញមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាដើម្បីត្រួតពិនិត្យមើលស្ថានភាពសិទ្ធិមនុស្សដោយខ្លួនលោកផ្ទាល់។ ទោះបីជា ប្រភពអង្គការសហប្រជាជាតិបាននិយាយនៅខែធ្នូ ថា លោក បណ្ឌិត វ៉ាល់ហែម និងធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជានៅដើមឆ្នាំ១៩៧៩ក៏ដោយ ក៏ការវិវត្តន៍សង្គ្រាមរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម បានបង្ខំឲ្យលោកបណ្ឌិត វ៉ាល់ហែម លុបចោលទស្សនកិច្ចរបស់លោកវិញ៕"

" UN Inquiry into Violations of Human Rights in Cambodia

Mr. Evan Luard, British Under-Secretary of State for Foreign and Commonwealth Affairs, proposed to the UN Human Rights Commission on March 3, 1978, that a special body should be set up to inquire into alleged violations of human rights in Cambodia. After the Soviet delegate had opposed the proposal, describing the allegations without basis and politically inspired, the commission decided on March 8 to ask the Cambodian Government to provide information on reports of serious abuses.

A statement issued by the Cambodian Foreign Ministry on April 22 condemned the British Government's initiative as 'odious interference', and described the British as 'very savage and very barbarous'.

The UN Subcommission on Prevention of Discrimination and Protection of Minorities adopted on Sep. 15 a resolution calling for an analysis of 1,000 pages of material on violation of human rights in Cambodia submitted by the British, US, Canadian and Norwegian Governments, by Amnesty International and by the International Commission of Jurists; the resolution was approved by 15 votes to three – Bulgaria, Romania and the Soviet Union voting against and Syria and Turkey abstaining. In a telegram to the UN Mr. Ieng Sary denounced the resolution as 'impudent interference' in Cambodia's internal affairs, and declared that the Cambodian people and Government would 'make mincemeat of any criminal manoeuvres of the imperialists and their partisans'. The analysis of the evidence, which was

submitted to the Human Rights Commission on Feb. 15, 1979, quoted estimates that a least 1,000,000 people had died in Cambodia from all causes since 1975.

Mr. Ieng Sary invited Dr. Kurt Waldheim, the UN Secretary-General, on Oct. 13, 1978, to visit Cambodia and verify the human rights situation for himself. Although the UN sources said in December that Dr. Waldheim would visit Cambodia at the beginning of 1979, the development of the war between Cambodia and Vietnam obliged him to cancel his visit."

Source: *Keesing's Contemporary Archives*, 4 May 1979, page 29583